**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**NATION RELIGION KING**

ក្រុមហ៊ុនមេធាវី គម្រាច្បាប់
LEGAL CODE LAW FIRM

# លិខិតជូនដំណឹង

ខ្ញុំបាទមេធាវី **មួន សៀងលី** សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ **១២២៩** ទីស្នាក់ការ **ក្រុមហ៊ុនមេធាវី គម្រាច្បាប់** អាសយដ្ឋានផ្ទះលេខ១៨១ ផ្លូវ១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីតំណាងឱ្យ **ក្រុមហ៊ុន** ZHONGGUANG CONSTRUCTION GROUP COMPANY ដែលមានអ្នកតំណាងលោក LIN YONGFEI ។

## សូមជម្រាបមក

**លោក ឡុង ហ្វីលីប នាយកប្រតិបត្តិក្រុមហ៊ុន** M.P.L IMPORT EXPORT & TRANSPORTATION CO., LTD.

អាសយដ្ឋាន៖ ផ្ទះលេខ៩១E០E១ បុរីប៉េងហួត ផ្លូវ០៥ភូមិដំណាក់ធំ១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០៧៨ ៩៩ ៥៩ ៩៩ ។

**កម្មវត្ថុ** ៖ ១. រំលោយកិច្ចសន្យាម៉ៅការចាក់បំពេញដី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ និងកិច្ចព្រមព្រៀង ដែលមានចែងនៅក្នុងកំណត់ហេតុប្រជុំរវាងគូភាគី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ រវាង **ក្រុមហ៊ុន** ZHONGGUANG CONSTRUCTION GROUP COMPANY និង **ក្រុមហ៊ុន** M.P.L IMPORT EXPORT & TRANSPORTATION CO., LTD ។

២. ទូទាត់ប្រាក់សំណងនៃការខូចខាតចំនួន $៣០,០០០ (បីម៉ឺនដុល្លារអាមេរិក) ដែលបណ្តាលមកពីការអនុវត្តកាតព្វកិច្ចយឺតយ៉ាវហួសហេតុ ចំនួន ៣៧ ថ្ងៃ ជាមួយនឹងទឹកប្រាក់ចុងក្រោយដែលត្រូវប្រគល់ជូន **ក្រុមហ៊ុន** M.P.L IMPORT EXPORT & TRANSPORTATION CO., LTD ចំនួន $១៦១,៨២៧ (ដប់ប្រាំមួយម៉ឺនមួយពាន់ប្រាំបីរយម្ភៃប្រាំពីរដុល្លារអាមេរិក) ។

**យោង** ៖ -កិច្ចសន្យាម៉ៅការចាក់បំពេញដី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ រវាង **ក្រុមហ៊ុន** ZHONGGUANG CONSTRUCTION GROUP COMPANY និង **ក្រុមហ៊ុន** M.P.L IMPORT EXPORT & TRANSPORTATION CO., LTD. ។

-កិច្ចព្រមព្រៀង ដែលមាននៅក្នុងកំណត់ហេតុប្រជុំរវាងគូភាគី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ រវាង **ក្រុមហ៊ុន** ZHONGGUANG CONSTRUCTION GROUP COMPANY និង **ក្រុមហ៊ុន** M.P.L IMPORT EXPORT & TRANSPORTATION CO., LTD. ។

-លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាង ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ២០២១ របស់លោក LIN YONGFEI ។



អាសយដ្ឋាន : ផ្ទះលេខ ១៨១ ផ្លូវ ១៥០ សង្កាត់ ទឹកល្អក់ទី ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ
Address: #181, St.150, Sangkat Tuek L'ak Ti Pir, Khan Toul Kork, Phnom Penh.
Tel: (+855) 86 262 630 / 92 299 934
E-mail : info@legalcodecambodia.com

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទជាមេធាវីតំណាងឱ្យក្រុមហ៊ុន ZHONGGUANG CONSTRUCTION GROUP COMPANY (តទៅនេះហៅកាត់ថា "**ក្រុមហ៊ុន ZHONGGUANG**") ដែលមានលោក LIN YONGFEI ជានាយកប្រតិបត្តិ សូមជម្រាបមក លោក **ឡុង ហ៊ីលីប** ដែលជានាយកប្រតិបត្តិនៃ**ក្រុមហ៊ុន M.P.L IMPORT EXPORT & TRANSPORTATION CO., LTD.** (តទៅនេះហៅកាត់ថា "**ក្រុមហ៊ុន M.P.L**") ឱ្យបានជ្រាបថា៖ ផ្អែកតាមកិច្ចសន្យាម៉ៅការចាក់បំពេញដី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ភាគី **ខ** ដែលជា**ក្រុមហ៊ុន M.P.L** ត្រូវមានកាតព្វកិច្ចចាក់បំពេញដីឱ្យ**ក្រុមហ៊ុន** ZHONGGUANG ចំនួន ៥៥០,០០០ ម៉ែត្រគីប ជា ៣ ដំណាក់កាលធំៗ ។ ជាក់ស្តែង នៅក្នុងដំណាក់កាលទី១ គឺ**ក្រុមហ៊ុន M.P.L** ត្រូវមានកាតព្វកិច្ចចាក់បំពេញដីឱ្យគ្រប់ចំនួន ១៦០,០០០ ម៉ែត្រគីប ក្នុងរយៈពេល **៥៥ ថ្ងៃ** គិតចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ។ ប៉ុន្តែ ផ្ទុយទៅវិញ**ក្រុមហ៊ុន M.P.L** ពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ស្របតាមពេលវេលាដែលបានកំណត់នោះឡើយ ។ ចំពោះករណីនេះ **ក្រុមហ៊ុន** ZHONGGUANG និង **ក្រុមហ៊ុន** M.P.L បានជួបប្រជុំដោះស្រាយវិវាទ និង បានបង្កើតនូវការព្រមព្រៀងបំពេញបន្ថែម និង កែប្រែនូវចំណុចខ្លះនៃកិច្ចសន្យាម៉ៅការចាក់បំពេញដី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ដូចមានចែងនៅក្នុងកំណត់ហេតុប្រជុំ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ។ តាមរយៈការព្រមព្រៀងថ្មីនេះ គឺ**ក្រុមហ៊ុន** M.P.L ត្រូវចាក់បំពេញដីឱ្យបានយ៉ាងតិច ឬ អាចលើសពីចំនួន ៣០,១០០.២ ម៉ែត្រគីប នៅក្នុងរយៈពេល **០៧ ថ្ងៃ** គិតចាប់ពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ហើយនឹងត្រូវអនុវត្តកាតព្វកិច្ចបែបនេះជាបន្តបន្ទាប់ រហូតដល់គ្រប់ចំនួន ១៦០,០០០ ម៉ែត្រគីប នៅក្នុងរយៈពេល **៥៥ ថ្ងៃ** ជាកំហិត ដែលត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ។ ជាក់ស្តែង រហូតមកដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ទើប**ក្រុមហ៊ុន** M.P.L បានប្រគល់លទ្ធផលការងារជូនមក**ក្រុមហ៊ុន** ZHONGGUANG ប៉ុន្តែមិនទាន់ចប់សព្វគ្រប់ ដោយត្រូវបំពេញបន្ថែមនូវការងារដែលសេសសល់ ជាអាទិ៍ ចាក់បំពេញដីកន្លែងមានទឹកដក់ឱ្យរួច, ឈូសបំពេញដីផ្នែកខាងក្រោយ, ធ្វើនៅផ្នែកខាងស្តាំដៃនៃផ្លូវចូលជិតដើមប្រេងខ្យល់ និង ធ្វើរបងស័ង្កសីឱ្យបានរួចរាល់ ។ ដូច្នេះ ក្រោយផុតរយៈពេល ៥៥ ថ្ងៃ គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ គឺ **ក្រុមហ៊ុន** M.P.L មានការយឺតយ៉ាវខ្លាំង រហូតដល់ចំនួន **៣៧ ថ្ងៃ** ដែលនឹងត្រូវពិន័យក្នុងមួយថ្ងៃចំនួន $៥,០០០ សរុបចំនួន $១៨៥,០០០ (ដប់ប្រាំបីម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ។ ប៉ុន្តែ ជាការអនុគ្រោះចំពោះការយឺតយ៉ាវនេះ **ក្រុមហ៊ុន** ZHONGGUANG បានសម្រេចបន្ថយទំហំប្រាក់ពិន័យនេះ មកត្រឹមតែចំនួន $៣០,០០០ (បីម៉ឺនដុល្លារអាមេរិក) តែប៉ុណ្ណោះ ដោយរួមបញ្ចូលទាំងការខូចខាតផ្សេងៗ ដែលមាននៅទីតាំងការដ្ឋានផ្ទាល់ ជាអាទិ៍ ការចំណាយរបស់**ក្រុមហ៊ុន** ZHONGGUANG លើការខូចខាតផ្សេងៗ ដែលកើតពីកំហុសរបស់**ក្រុមហ៊ុន** M.P.L ក្នុងអំឡុងពេលដំណើរការការដ្ឋាន ...។ល។

ចំពោះប្រាក់ពិន័យនៃការយឺតយ៉ាវនេះ **ក្រុមហ៊ុន** ZHONGGUANG បានសម្រេចធ្វើការទូទាត់ដោយផ្ទាល់ជាមួយនឹងទឹកប្រាក់ ដែលត្រូវប្រគល់ជូន **ក្រុមហ៊ុន** M.P.L ចុងក្រោយ ចំនួន $១៦១,៨២៧ (ដប់ប្រាំមួយម៉ឺនមួយពាន់ប្រាំបីរយម្ភៃប្រាំពីរដុល្លារអាមេរិក) ជាថ្លៃចាក់បំពេញដីចំនួន ១៦០,០០០ ម៉ែត្រគីប ។ ជាក់ស្តែង ចំពោះការបង្ហាញឆន្ទៈអំពីការទូទាត់នេះ កន្លងទៅ**ក្រុមហ៊ុន** ZHONGGUANG បានធ្វើការជូនដំណឹងដោយផ្ទាល់មាត់រួចរាល់ហើយទៅកាន់ **ក្រុមហ៊ុន** M.P.L ហើយក៏បានធ្វើសំណើផ្តល់ការសងផងដែរ ចំពោះកាតព្វកិច្ចបង់ថ្លៃម៉ៅការជូន**ក្រុមហ៊ុន** M.P.L តាំងពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ក្រោយពី**ក្រុមហ៊ុន** M.P.L បានបំពេញបន្ថែមនូវការងារសេសសល់នៃលទ្ធផលការងាររួចរាល់ ជាអាទិ៍ ចាក់បំពេញដីកន្លែងមានទឹកដក់ឱ្យរួច, ឈូសបំពេញដីផ្នែកខាងក្រោយ, ធ្វើនៅផ្នែកខាងស្តាំដៃនៃផ្លូវចូលជិតដើមប្រេងខ្យល់ និងធ្វើរបងស័ង្កសីឱ្យបានរួចរាល់ ។ ប៉ុន្តែ

ជាក់ស្តែងត្រូវបាន**ក្រុមហ៊ុន M.P.L** បដិសេធមិនព្រមទទួលការសងនោះទេ ហើយទាមទារឱ្យ**ក្រុមហ៊ុន ZHONGGUANG** បង់ថ្លៃឱ្យបានពេញលេញ និងមិនឱ្យធ្វើការទូទាត់ប្រាក់ពិន័យចំពោះការយឺតយ៉ាវនោះឡើយ ។ ប៉ុន្តែ ទោះជាយ៉ាងណា យោងតាមមាត្រា **៤៦៤** កថាខណ្ឌទី ១ និងមាត្រា **៤៦៥** នៃក្រមរដ្ឋប្បវេណី គឺបានបញ្ញត្តិអំពីការទូទាត់ ត្រូវធ្វើឡើងត្រឹមតែជាការបង្ហាញឆន្ទៈទូទាត់ពីភាគីម្ខាង ទៅភាគីម្ខាងទៀតតែប៉ុណ្ណោះ ។ ដូច្នេះ អានុភាពនៃការទូទាត់ខាងលើនេះ គឺនាំឱ្យកាតព្វកិច្ចដែល**ក្រុមហ៊ុន ZHONGGUANG** ត្រូវបង់ថ្លៃម៉ៅការលើកចុងក្រោយនោះ នៅសល់ទឹកប្រាក់ចំនួន $១៣១,៨២៧ (ដប់បីម៉ឺនមួយពាន់ប្រាំបីរយម្ភៃប្រាំពីរដុល្លារអាមេរិក) ហើយ**ក្រុមហ៊ុន ZHONGGUANG** នឹងធ្វើការប្រគល់ឱ្យទៅ**ក្រុមហ៊ុន M.P.L** តាមរយៈមូលប្បទានបត្រ ក្នុងរយៈពេល **០៣ ថ្ងៃ** ក្រោយពី**ក្រុមហ៊ុន M.P.L** ទទួលបានលិខិតជូនដំណឹងនេះ ហើយ**ក្រុមហ៊ុន M.P.L** ត្រូវធ្វើការជូនដំណឹងមក**ក្រុមហ៊ុន ZHONGGUANG** វិញ មុននឹងមកទទួលប្រាក់ថ្លៃម៉ៅការលើកចុងក្រោយនេះ ។

ជាការពិត **ក្រុមហ៊ុន M.P.L** មានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច តាំងពីចាប់ផ្តើមចុះកិច្ចសន្យាម៉ៅការចាក់បំពេញដី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ មកម្ល៉េះ បើទោះបីមានការអនុគ្រោះតាមរយៈការចូលរួមដោះស្រាយវិវាទ និងព្រមព្រៀងអនុវត្តកាតព្វកិច្ចជាថ្មី ដូចដែលមានចែងនៅក្នុងកំណត់ហេតុប្រជុំរវាងគូភាគី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ យ៉ាងណាក៏ដោយ ក៏**ក្រុមហ៊ុន M.P.L** នៅតែបន្តការយឺតយ៉ាវរហូត ។ ជាក់ស្តែង ដោយមូលហេតុនៃការអនុវត្តកាតព្វកិច្ចយឺតយ៉ាវហួសហេតុរបស់**ក្រុមហ៊ុន M.P.L** នៅក្នុងការចាក់បំពេញដីដំណាក់កាលទី១ ចំនួន ១៦០,០០០ ម៉ែត្រគីប នេះ គឺបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍របស់**ក្រុមហ៊ុន ZHONGGUANG** យ៉ាងធ្ងន់ធ្ងរ ។ ម្យ៉ាងទៀត **ក្រុមហ៊ុន ZHONGGUANG** បានបាត់បង់ទំនុកចិត្តលើ**ក្រុមហ៊ុន M.P.L** នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងតទៅទៀត និង មិនមានភាពជឿជាក់ថា **ក្រុមហ៊ុន M.P.L** អាចនឹងបន្តអនុវត្តកាតព្វកិច្ចឱ្យបានត្រឹមត្រូវ និង ពេញលេញ ទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងបាននោះឡើយ ។ លើសពីនេះ **ក្រុមហ៊ុន M.P.L** បានបង្កការរំខានជាច្រើននៅក្នុងការអនុវត្តកាតព្វកិច្ច ជាអាទិ៍ តាមរយៈការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាមួយអ្នកផ្គត់ផ្គង់ប្រេង អ្នកម៉ៅការបន្តរបស់**ក្រុមហ៊ុន M.P.L** នៅក្នុងការឈូសឆាយចាក់បំពេញដីជាដើម ដូចជា ការមកបង្កការរំខាន នៅក្នុងការទាមទារប្រាក់ផ្សេងៗ ដែលជាកាតព្វកិច្ចរបស់**ក្រុមហ៊ុន M.P.L** នៅទីតាំងការដ្ឋាន ។ ជាក់ស្តែង តាមរយៈការមិនអនុវត្តកាតព្វកិច្ចទាំងនោះ ទើប**ក្រុមហ៊ុន M.P.L** បានទទួលរងនូវបណ្តឹងចោទប្រកាន់ផ្នែកព្រហ្មទណ្ឌជាច្រើន ពាក់ព័ន្ធនឹងការចេញនូវមូលប្បទានបត្រគ្មានសាច់ប្រាក់ជាដើម ដែលឈានទៅដល់ការចាប់ខ្លួន**លោក ឡុង ហ៊ីលីប** កាលពីថ្មីៗនេះ ។

ដូច្នេះ ផ្អែកតាមមាត្រា **៤០៧** និងមាត្រា **៤០៨** នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និង មូលហេតុដូចមានរៀបរាប់ខាងលើ **ក្រុមហ៊ុន ZHONGGUANG** សូមធ្វើការរំលាយកិច្ចសន្យាម៉ៅការ និងកិច្ចព្រមព្រៀង ដែលមានចែងនៅក្នុងកម្មវត្ថុខាងលើនេះ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះតទៅ ។ មួយវិញទៀត គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ **ក្រុមហ៊ុន ZHONGGUANG** នឹងអនុវត្តសិទ្ធិនៅក្នុងការស្វែងរកអ្នកម៉ៅការថ្មី ហើយក្រុមហ៊ុន M.P.L ត្រូវចាកចេញ និង ដកចេញនូវសម្ភារ និងគ្រឿងចក្រផ្សេងៗ ចេញពីទីតាំងការដ្ឋាន និងមិនត្រូវបង្កការរំខាន ឬ ធ្វើសកម្មភាពរារាំងណាមួយឡើយ ។ ក្នុងករណីដែល **ក្រុមហ៊ុន M.P.L** នៅតែមិនអនុវត្តតាមការជូនដំណឹងនេះទេ ក្នុងនាមខ្ញុំជាមេធាវីតំណាងឱ្យ**ក្រុមហ៊ុន ZHONGGUANG** នឹងចាត់វិធានការតាមនីតិវិធីច្បាប់ជាអាទិ៍ ***ប្តឹងទៅតុលាការរដ្ឋប្បវេណី និងតុលាការព្រហ្មទណ្ឌ ប្រសិនបើមានបទល្មើស ដើម្បីធ្វើការចាត់ការជាបន្ទាន់ ព្រមទាំងធ្វើចំណាត់ការនីតិវិធីអនុវត្តដោយបង្ខំឱ្យធ្វើការរុះរើ ដោយកម្លាំងសាធារណៈតាមផ្លូវតុលាការ និង ចំណាត់ការនីតិវិធីច្បាប់ ដែលចាំបាច់ផ្សេងៗទៀត ដើម្បីបង្ក្រាបចំពោះការរំលោភបំពាន ។***

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក ឡុងហ្វីលីប** មេត្តាជ្រាបជាព័ត៌មាន និង ទទួលយកការអនុវត្តតាមខ្លឹមសារនៃការជូនដំណឹងខាងលើនេះ ឱ្យបានត្រឹមត្រូវ និងសមស្របបំផុត ។

សូម **លោក ឡុងហ្វីលីប** ទទួលនូវការគោរពរាប់អាន អំពីខ្ញុំបាទ ។

ថ្ងៃអង្គារ ២ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**មេធាវី.មួន សៀងលី**